Australian Competition & Consumer Commission

# គុក!គុក! តើអ្នកណាគេហ្នឹង?



ការណែនាំសំរាប់អ្នកប្រើប្រាស់ចំពោះការលក់ដូរពីផ្ទះមួយទៅផ្ទះមួយ

# ដឹងអំពីសិទ្ធិរបស់លោកអ្នកនៅពេលដែលអ្នកលក់ដូរមកគោះទ្វារ

**លោកអ្នកមានសិទ្ធិត្រឹមត្រូវតាមច្បាប់នៅពេលដោះស្រាយជាមួយអ្នកលក់ដូរនៅមាត់ទ្វាររបស់លោកអ្នក។**

**ប្រសិនបើការឲ្យថ្លៃមានតម្លៃលើសពី $100 (ឬក៏តម្លៃនេះមិនអាចកំណត់បាននៅពេល គេឲ្យថ្លៃ), អ្នកលក់ដូរនេះត្រូវប្រព្រឹត្តតាមច្បាប់:**

- របៀបនិងពេលដែលគេអាចមកគោះទ្វារបាន
- ព័ត៌មានអ្វីខ្លះដែលគេត្រូវផ្តល់ជូនលោកអ្នក
- សិទ្ធិលោកអ្នកដើម្បីផ្លាស់ប្តូរគំនិតរបស់លោកអ្នក។

**ប្រសិនបើលោកអ្នកស្នើសុំឲ្យអ្នកលក់ដូរពីផ្ទះមួយទៅផ្ទះមួយចាកចេញ, គេត្រូវតែ:**

- ចាកចេញភ្លាម, ហើយ
- មិនត្រូវត្រឡប់មកវិញក្នុងរយៈពេល 30 ថ្ងៃ។

**អ្នកលក់ដូរពីផ្ទះមួយទៅផ្ទះមួយពុំអាចមកចូលជួបលោកអ្នកបានទេគឺ:**

- នៅថ្ងៃអាទិត្យ ឬថ្ងៃបុណ្យសាធារណៈ;
- មុនម៉ោង 9 ព្រឹកឬក្រោយម៉ោង 6 ល្ងាចក្នុងថ្ងៃសប្តាហ៍
- មុនម៉ោង 9 ព្រឹក ឬក្រោយម៉ោង 5 ល្ងាចនៅថ្ងៃសៅរ៍។

**សូមឆែកមើលប័ណ្ណអត្តសញ្ញាណរបស់អ្នកលក់ដូរ។ តាមច្បាប់គេត្រូវតែជំរាបលោកអ្នកនូវ:**

- ឈ្មោះរបស់គេ
- ព័ត៌មានលំអិតអំពីទំនាក់ទំនងពាណិជ្ជកម្មដែលគេជាតំណាង
- ហេតុអ្វីបានជាគេមកដល់ទ្វាររបស់លោកអ្នក។

**ពុំចង់ឲ្យអ្នកលក់ដូរមកគោះទ្វារលោកអ្នកឬ? សូមបិទស្លាកប្រកាសមួយនៅកន្លែងមើលឃើញច្បាស់កៀរទ្វារចូល របស់លោកអ្នក។ ស្លាក "សូមកុំគោះទ្វារ" នេះអាចរកបានតាមវេបសៃ www.accc.gov.au/doortodoor**

## គិតនិញអ្វីមួយឬ?

**ប្រសិនបើលោកអ្នកសម្រេចចិត្តទិញនៅមាត់ទ្វាររបស់លោកអ្នក, អ្នកលក់ដូរត្រូវតែផ្តល់ជូនលោក អ្នកនូវកិច្ចព្រមព្រៀងមួយ។**

**ឯកសារនេះត្រូវតែ:**

- សរសេរភាសាយ៉ាងច្បាស់និងសាមញ្ញ, និងរួមមានលក្ខខណ្ឌពេញលេញ
- ប្រាប់តម្លៃសរុប(រួមមានទាំងថ្លៃប៉ុស្តិ៍ឬថ្លៃយកមកឲ្យ), ឬរបៀបគិតតម្លៃនេះ
- មានព័ត៌មានលំអិតអំពីទំនាក់ទំនងរបស់អ្នកលក់ដូរនិងអ្នកផ្គត់ផ្គង់
- ត្រូវបានចុះហត្ថលេខាដោយលោកអ្នកនិងអ្នកលក់ដូរ
- មានព័ត៌មានអំពីសិទ្ធិរបស់លោកអ្នកក្នុងការលុបចោលកិច្ចព្រមព្រៀង, និងពាក្យសំរាប់ប្រើសិទ្ធិទាំងនេះ ប្រសិនបើលោកអ្នកផ្លាស់ប្តូរគំនិតលោកអ្នក។

**តើលោកអ្នកបានឆែកមើលហើយប្រៀបធៀបតម្លៃជាមួយកន្លែងផ្សេងទៀតឬទេ? សូមធ្វើឲ្យប្រាកដ ថាលោកអ្នកទទួលបានតម្លៃថោកបំផុត – សូមឆែកមើលថាតើមានគេលក់ចុះថ្លៃនៅកន្លែងផ្សេងទៀតដែរឬទេ។**

## វាមិនជាអ្វីទេក្នុងការផ្លាស់ប្តូរគំនិតលោកអ្នក

**ពេលលោកអ្នកទិញអ្វីមួយនៅមាត់ទ្វាររបស់លោកអ្នក, លោកអ្នកទទួលដោយស្វ័យប្រវត្តិនូវសិទ្ធិ “មានពេលធ្វើការសម្រេចចិត្ត” :**

- លោកអ្នកអាចផ្លាស់ប្តូរគំនិតរបស់លោកអ្នកហើយលុបចោលកិច្ចសន្យាសំរាប់មូលហេតុ ណាមួយដោយគ្មានពិន័យទេនៅក្នុងរយៈពេល 10 ថ្ងៃអាជីវកម្ម។ នេះគេហៅថាអំឡុងពេល “មានពេលធ្វើការសម្រេចចិត្ត” ហើយអ្នកលក់ដូរត្រូវតែជំរាបលោកអ្នកអំពីករណីនេះមុនពេល លោកអ្នកចុះហត្ថលេខា។
- ទោះបីជាអ្នកលក់ដូរផ្តល់ផលិតផលនៅក្នុងអំឡុងពេលនេះក៏ដោយ, លោកអ្នកក៏នៅអាច “មានពេលធ្វើការសម្រេចចិត្ត” បានដែរ។
- អ្នកលក់ដូរទាំងឡាយពុំអាចយកប្រាក់នៅក្នុងអំឡុងពេល “មានពេលធ្វើការសម្រេចចិត្ត” ឡើយ លើកលែងតែចំពោះការផ្តល់នូវថាមពល។



ក្នុងករណីខ្លះ, សិទ្ធិ “មានពេលធ្វើការសម្រេចចិត្ត” របស់លោកអ្នកប្រហែលជាមានរយៈពេលវែងជាងនេះ ប្រសិនបើអ្នក លក់ដូរនេះមិនបានប្រព្រឹត្តតាមច្បាប់។

ដើម្បីលុបចោលកិច្ចព្រមព្រៀងនេះ, សូមនិយាយប្រាប់ឈ្មួញតាមពាក្យសម្តី ឬសរសេរជាលាយលក្ខណ៍អក្សរថាលោកអ្នកពុំចង់បន្តការលក់ដូរនេះតទៅទៀតទេ។

**តើលោកអ្នកដឹងឬទេថាលោកអ្នកនៅតែអាចឆែកមើលតម្លៃបានទៀតទោះជានៅក្រោយការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនៃការលក់ដូរពីផ្ទះមួយទៅផ្ទះមួយនោះក៏ដោយ? សូមឆ្លៀតយកប្រយោជន៍នៃអំឡុងពេល “មានពេលធ្វើការសម្រេចចិត្ត” ដើម្បីធ្វើឲ្យប្រាកដថានេះជាតម្លៃថោកបំផុតសំរាប់លោកអ្នក។**

# សិទ្ធិបន្ថែម

**បន្ថែមពីលើសិទ្ធិទាំងឡាយដែលបានផ្តល់នូវចំណុចសំខាន់ៗរួចមកហើយនោះ, លោកអ្នកក៏មាន សិទ្ធិ ដែលបានរំពឹងទុកផងដែរគឺ:**

- ការតំណាងដែលសុច្ចៈនិងពិត — អ្នកលក់ដូរពុំអាចនាំឲ្យលោកអ្នកយល់ខុស ឬបោកលោកអ្នកទេ
- ការប្រព្រឹត្តសមហេតុផល — អ្នកលក់ដូរពុំអាចធ្វើអ្វីមួយដោយមិនសមស្របចំពោះលោកអ្នកបានទេ
- ផលិតផល និងសេវាកម្មនឹងអនុវត្ត ឬបំពេញមុខការដូចដែលវាត្រូវធ្វើ — បើមិនដូច្នោះ ទេ, លោកអ្នកអាចមានសិទ្ធិសុំឲ្យគេជួសជុល, ផ្លាស់ប្តូរ ឬសងប្រាក់មកវិញ។

## នៅក្នុងស្ថានភាពខ្លះ, ការការពារបន្ថែមត្រូវអនុវត្ត

- នៅក្នុងរដ្ឋខ្លះនិងដែនដី, ការការពារបន្ថែមត្រូវអនុវត្តលើការលក់ដូរថាមពល។ ដើម្បីឲ្យបានដឹងច្រើនថែមទៀត សូមបើកមើលនៅតាមវើបសៃរបស់និយតករថាមពលអូស្ត្រាលី www.aer.gov.au
- ជាទូទៅវាជាការខុសច្បាប់ចំពោះអ្នកលក់ដូរដែលលក់ឱវាទខាងហិរញ្ញវត្ថុ ឬផលិតផលនៅ មាត់ទ្វាររបស់លោកអ្នកដោយពុំមានការអញ្ជើញជាមុន។



# ព័ត៌មានថែមទៀត

Australian Competition and Consumer Commission

www.accc.gov.au

មជ្ឈមណ្ឌលផ្តល់ព័ត៌មាន 1300 302 502

ខ្សែទូរស័ព្ទផ្តល់ព័ត៌មានអន្តោប្រាម 1300 303 143

កិច្ចបំរើការបកប្រែភាសានិយាយនិងសរសេរ 13 1450

ទូរស័ព្ទសំរាប់អ្នកអន់ខ្សោយក្នុងការស្តាប់ឮ(TTY) 13 3677

និយាយនិងស្តាប់ (Speak and Listen) 1300 555 727

អ៊ិនធឺណេតបញ្ជូនត www.relayservice.com.au

**ដើម្បីឲ្យបានដឹងច្រើនថែមទៀត, សូមឆែកមើល *ការលក់ដូរពីផ្ទះមួយទៅផ្ទះមួយរបស់* ACCC: *ការបោះពុម្ពផ្សាយនៃការណែនាំសំរាប់អ្នកប្រើប្រាស់*— អាចរកបាននៅតាមវេបសៃ www.accc.gov.au/doortodoor ។**

Australian Competition and Consumer Commission
23 Marcus Clarke Street, Canberra, Australian Capital Territory 2601

© Commonwealth of Australia 2012

**ប្រកាសដ៏សំខាន់**

ព័ត៌មាននៅក្នុងការបោះពុម្ពផ្សាយនេះគឺជាការណែនាំទូទៅប៉ុណ្ណោះ។ ការបោះពុម្ពផ្សាយនេះពុំមែន បង្កើតជាឱវាទតាមផ្លូវច្បាប់ឬជាឱវាទខាងវិជ្ជាជីវៈទេ, ហើយពុំគួរពឹងផ្អែកថាជាសេចក្តីថ្លែងនៃច្បាប់ ក្នុងនីតិកម្មណាមួយនោះឡើយ។ ដោយសារការបោះពុម្ពផ្សាយនេះត្រូវបានគ្រោងទុកជាការណែនាំទូទៅ ប៉ុណ្ណោះ, វាអាចនៅមានការធ្វើឲ្យទៅជាលក្ខណៈទូទៅ។ លោកអ្នកគួរស្វែងរកឱវាទខាងវិជ្ជាជីវៈ ប្រសិនបើលោកអ្នកមានកង្វល់ជាក់លាក់ណាមួយ។

ACCC បានធ្វើឲ្យអស់ការខិតខំប្រឹងប្រែងសមហេតុផលដើម្បីផ្តល់ព័ត៌មានថ្មីៗនិងច្បាស់លាស់, ក៏ប៉ុន្តែអង្គការនេះមិនធ្វើការធានាណាមួយចំពោះភាពត្រឹមត្រូវ, ភាពទាន់ពេលទាន់វេលា ឬភាពពេញលេញនៃព័ត៌មាននោះឡើយ។

ISBN 978 1 921973 20 8

ACCC 08/12_32325_591

# សូមចងចាំថា

- វាមិនជាអីទេដែលត្រូវនិយាយថាទេ—ប្រសិនបើអ្នកលក់ដូរចាប់ទាក់ទងជាមួយ លោកអ្នកនៅមាត់ទ្វារលោកអ្នក, លោកអ្នកមិនត្រូវយល់ស្របទៅចំពោះអ្វីមួយឡើយ។
- ប្រសិនបើលោកអ្នកចង់ឲ្យអ្នកលក់ដូរចាកចេញ, សូមប្រាប់គេ—នោះគេត្រូវតែចាកចេញភ្លាម។
- លោកអ្នកមិនត្រូវយល់ស្របទៅចំពោះអ្វីមួយនៅនឹងកន្លែងភ្លាមៗឡើយ—ប្រសិនបើលោកអ្នកមានអារម្មណ៍ថាគេបង្ខំឲ្យចុះហត្ថលេខាលើអ្វីមួយ, សូមប្រាប់អ្នកលក់ថាលោកអ្នកត្រូវការ ពេលគិតមើលពីការឲ្យតម្លៃនោះសិន។
- ប្រសិនបើលោកអ្នកគិតផ្លាស់ប្តូរសាប័នផ្តល់កិច្ចបំរើ, ដូចជា កិច្ចបំរើខាងថាមពល ឬខាងទូរស័ព្ទ, សូមទាក់ទងស្ថាប័នបច្ចុប្បន្នរបស់លោកអ្នកដើម្បីឆែកមើលថាតើលោកអ្នក មានចុះហត្ថលេខាលើពេលវេលាដែលមានកំណត់ហើយថាតើថ្លៃលុបចោលកិច្ចព្រមព្រៀងនឹងត្រូវអនុវត្តឬទេ។
- វាមិនជាអីទេដែលផ្លាស់ប្តូរគំនិតលោកអ្នក—ប្រសិនបើលោកអ្នកយល់ព្រមទិញពីអ្នកលក់ ដូរពីផ្ទះមួយទៅផ្ទះមួយ ក៏ប៉ុន្តែក្រោយមកសម្រេចចិត្តថាការឲ្យថ្លៃនោះមិនសមចំពោះ លោកអ្នកទេនោះ, សូមគ្រាន់តែប្រើសិទ្ធិ "មានពេលធ្វើការសម្រេចចិត្ត" របស់លោកអ្នកប៉ុណ្ណោះ។

